**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៦ អនក្រ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតក្រុមការងារសិក្សា វាយតម្លៃ តំបន់អភិវឌ្ឍន៍អាងទឹកស្អាត**
**និងរមណីយដ្ឋានក្បាលឆាយ ក្រុងព្រះសីហនុ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**ស ម្រេ ច .**

**ប្រការ ១ :** ត្រូវបានបង្កើតក្រុមការងារសិក្សា វាយតម្លៃ តំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ក្រុងព្រះសីហនុ ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **ស្វាយ ស៊ីថា** | អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ប្រធាន |
| ២-ឯកឧត្តម **សួន សិទ្ធី** | អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |

| | | |
|---|---|---|
| ៣-ឯកឧត្តម **ហ៊ីង ថូរ៉ាក់ស៊ី** | នាយករងខុទ្ទកាល័យ និងជាទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤-ឯកឧត្តម **អ៊ុក សុខុន** | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥-ឯកឧត្តម **គោស៊ី សារឿត** | អគ្គនាយកបច្ចេកទេស ក្រសួងទេសចរណ៍ | សមាជិក |
| ៦-ឯកឧត្តម **ឡុញ ហ៊ាល** | អគ្គនាយកបច្ចេកទេស ក្រសួងបរិស្ថាន | សមាជិក |
| ៧-ឯកឧត្តម **ឌុច ទនទីតូ** | អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨- ឯកឧត្តម **ម៉ិន ហ៊ាន** | អគ្គនាយកកិច្ចការបច្ចេកទេស ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩- ឯកឧត្តម **ឈឹម សៅគី** | អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ១០-លោក **ប្រាក់ ស៊ីហារ៉ា** | អភិបាលរងក្រុងព្រះសីហនុ | សមាជិក |
| ១១-លោក **ម៉េង សក្តិធារ៉ា** | ប្រធាននាយកដ្ឋានទឹកស្អាត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១២-លោក **មុជ ជុំហ៊ាន** | ប្រធាននាយកដ្ឋានវារីអគ្គិសនី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៣-តំណាងក្រុមហ៊ុន **អាន ពូ** | | សមាជិក |

**ប្រការ ២** : ក្រុមការងារសិក្សា វាយតម្លៃ តំបន់អភិវឌ្ឍន៍អាងទឹកស្អាត និងរមណីយដ្ឋានក្បាលឆាយ ក្រុងព្រះសីហនុ មានភារកិច្ចដូចខាងក្រោម :

- ផ្តល់ការណែនាំជាទូទៅក្នុងការអនុវត្តគំរោងនានា ដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលក្នុងតំបន់ទីជំរាលក្បាល ឆាយ ក្រុងព្រះសីហនុ សំដៅគ្រប់គ្រងដោយនិរន្តរភាពនៃតំបន់ទីជំរាលក្បាលឆាយ
- ធ្វើការសំរបសំរួលជាមួយម្ចាស់គំរោង និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីឱ្យការអនុវត្តគំរោងនានាក្នុងតំបន់ទីជំរាលក្បាលឆាយ ប្រព្រឹត្តទៅដោយរលូន គ្មានឧបសគ្គ និងសម្រេចបានជោគជ័យ
- សិក្សា វាយតម្លៃផលប៉ះពាល់ជាទូទៅចំពោះតំបន់ទីជម្រាលក្បាលឆាយទាំងមូល និងជំរុញការសហការ រវាងអង្គភាព ស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាការគ្រប់គ្រងប្រកបដោយនិរន្តរភាព តំបន់ទីជំរាលក្បាលឆាយ ។

**ប្រការ ៣ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួង បរិស្ថាន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែង ក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ ៥/៧ ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល ៖***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ក្រុមហ៊ុន **អាន ពូ***
- *ដូចប្រការ ៣*
- *ឯកសារ-កាលប្បវត្តិ*